**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០១៥ សហវ.[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទដែលកំពុងចរាចរ ប្រើប្រាស់ ឬសន្និធិយានយន្តនៅតាមបណ្តាអាជីវកម្មដ្ឋាន លំនៅដ្ឋាន ឬកន្លែងផ្សេងទៀត ទូទាំងព្រះរាជាណាចក្រកម្ពុជាដែលខកខានដោយប្រការណាមួយក្នុងការបំពេញបែបបទបង់ពន្ធ និងអាករនាពេលនាំចូលស្របតាមច្បាប់ជាធរមានកន្លងមកឱ្យបានជ្រាបថា នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុគ្រោះឱ្យមានការចូលមកបំពេញកាតព្វកិច្ចពន្ធដោយស្ម័គ្រចិត្តលើយានយន្តប្រភេទដូចខាងលើនេះក្តី ដោយមានការពន្យាពេលជាបន្តបន្ទាប់ក្តី ក៏មានតែម្ចាស់យានយន្តចំនួនជាង ៣.០០០ គ្រឿងប៉ុណ្ណោះ បានអនុវត្តល្អតាមខ្លឹមសារនេះ ។ ដោយឡែកម្ចាស់យានយន្តមួយចំនួនទៀតនៅតែរារែកមិនទាន់ចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធនៅឡើយ ហើយម្ចាស់យានយន្តខ្លះបានប្រើរូបភាពក្លែងបន្លំឯកសារសំគាល់យានយន្តផ្សេងៗដូចជាបានប្រើលតាប័ត្រក្លែងក្លាយ ឬលតាប័ត្រខុសប្រភេទរថយន្ត ក៏ដូចជាផ្លាកលេខមិនស្របច្បាប់ប្រភេទថ្មី ឬប្រភេទចាស់ ដែលនាំឱ្យមានបទល្មើសធ្ងន់ធ្ងរបន្ថែមទៀតពីលើបទល្មើសគេចពន្ធដែលមានស្រាប់។

ចំពោះមុខបាតុភាពអសកម្មទាំងនេះនិងដើម្បីជៀសវាងនូវផលវិបាកជាយថាហេតុនានា ជាពិសេសក្នុងពេលដែលអាជ្ញាធរមានសមត្ថកិច្ចចុះបង្ក្រាប ឬចាប់ឃាត់នោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឱ្យម្ចាស់យានយន្តគ្រប់ប្រភេទដូចរៀបរាប់ខាងលើ ចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធឱ្យបានរួសរាន់នៅការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ ឬនៅតាមសាខាគយនិងរដ្ឋាករខេត្ត ក្រុង ទាំងអស់ដោយពុំរងការផាកពិន័យអ្វីឡើយ ។ សមត្ថកិច្ចគយនិងរដ្ឋាករ នឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដោយអនុលោមតាមការសំរេចរបស់រាជរដ្ឋាភិបាលដើម្បីដំណើរការបង្ក្រាបបទល្មើសទាំងនេះនៅតាមដងផ្លូវសាធារណៈ កន្លែងសន្និធិ និងនៅតាមលំនៅដ្ឋាន ក៏ដូចជាអាជីវកម្មដ្ឋាននានាជាបណ្តើរៗយ៉ាងម៉ឺងម៉ាត់ ដោយត្រូវចាប់ឃាត់ជាបណ្តោះអាសន្ននូវយានយន្តល្មើសច្បាប់ទាំងនេះបង្ខំឱ្យបង់ពន្ធ អាករ និងពិន័យតាមច្បាប់ជាធរមាន ដោយគ្មានការយោគយល់អ្វីឡើយ ហើយក្នុងករណីចាំបាច់បញ្ជូនករណីទាំងនេះទៅតុលាការមានសមត្ថកិច្ចដើម្បីផ្តន្ទាទោសតាមច្បាប់ ។

អាស្រ័យហេតុនេះសូមឱ្យម្ចាស់យានយន្តដូចរៀបរាប់ខាងលើ ចូលខ្លួនដោយស្ម័គ្រចិត្តមកអនុវត្តតាមខ្លឹមសារសេចក្តីជូនដំណឹងនេះប្រកបដោយក្តីយោគយល់គ្នាទៅវិញទៅមក ដោយចាត់ទុកទង្វើនេះជាការចូលរួមដោយផ្ទាល់ក្នុងការកសាងសង្គមនីតិរដ្ឋនៅកម្ពុជា។ សូមម្ចាស់យានយន្តដូចរៀបរាប់ខាងលើមកទំនាក់ទំនងនៅទីចាត់ការគយនិងរដ្ឋាករ (ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ ឬតាមទូរស័ព្ទលេខ ០១២ ៨២៨៧៧៧ - ០១២ ២៧៩៨៩៩ និងលេខ ០១២ ៤៧៨៩៩៩ រាល់ពេលម៉ោងធ្វើការ ។

នេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រធានគណៈកម្មការអន្តរក្រសួងទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ

គាត ឈន់

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់សាលាខេត្ត-ក្រុង
(ដើម្បីជូនជ្រាបជាព័តមាន)
- ឯកសារ-កាលប្បវត្តិ